# លិខិតបើកចំហ

## សូមគោរពជូន

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ទំនប់វារីអគ្គិសនី**ជាយអារ៉ែង**ជាទំនប់មួយទទួលបានការវិនិយោគពីក្រុមហ៊ុន ឆាយណា ហ្គូដៀន ខូធឺរេសិន (China Guodian Corporation) ដែលត្រូវបានចុះអនុស្សរណៈយោគយល់ជាមួយរាជរដ្ឋាភិបាលកម្ពុជានៅខែវិច្ឆិកា ឆ្នាំ ២០១០ បន្ទាប់ពីការដកខ្លួនចេញរបស់ក្រុមហ៊ុន ឆាយណា សាវជិន ផាវើគ្រីត ដោយសារតែគម្រោងអាចនឹងបង្កឲ្យមានផលប៉ះពាល់បរិស្ថានខ្លាំង។ ទំនប់នេះជាគម្រោង *សាងសង់ ប្រតិបត្តិ និង ផ្ទេរ (BOT)* ដែលនឹងត្រូវការពេល ៤,៥ ឆ្នាំ ដើម្បីសាងសង់ និងមានកំរិតសមត្ថភាព ១០៨ មេហ្គាវ៉ាត់ ចំណាយទឹកប្រាក់សរុប ៣២៧ លាន ដុល្លារសហរដ្ឋអាមេរិក[1]។ ទំនប់នេះគ្រោងនឹងសាងសង់ក្នុងភូមិ ព្រែកស្វាយ ឃុំថ្មបាំង ស្រុកថ្មបាំង ខេត្តកោះកុង។ ប៉ុន្តែតាមព័ត៌មានមិនផ្លូវការបានបញ្ជាក់ថាក្រុមហ៊ុន ឆាយណា ហ្គូដៀន ខូធឺរេសិន ប្រហែលជាមិនបន្តគម្រោងនេះទេ ហើយក្រុមហ៊ុន ស៊ីណូហាយដ្រូ (Sinohydro Co., Ltd) កំពុងតែពិចារណាទទួលយកគម្រោងវិនិយោគនេះបន្ត។ ទោះជាយ៉ាងណាក៏ដោយ ព័ត៌មានជាក់លាក់ចំពោះក្រុមហ៊ុនដែលនឹងមកជំនួសនោះគឺមិនទាន់មានប្រកាសជាផ្លូវការដោយរាជរដ្ឋាភិបាលកម្ពុជានូវឡើយទេ។

ប្រសិនបើទំនប់នេះត្រូវបានសាងសង់ នោះប្រជាជនប្រមាណ ៣៨៩ គ្រួសារ (១.៦៤២ នាក់)[2] និងព្រៃឈើប្រហែលជា ២០.០០០ ហិចតា នឹងរងផលប៉ះពាល់។ ជាងនេះទៅទៀត ថនិកសត្វប្រមាណជា ៥៧ប្រភេទ បក្សី ៩៣ប្រភេទ ល្មូន ៥៥ប្រភេទ (រួមទាំងក្រពើភ្នំ) ឧរង្គសត្វ ២៩ប្រភេទ និងត្រី៤៣ប្រភេទ (រួមទាំងត្រីនាគ) និងត្រូវបានគំរាមកំហែងដោយសារការសាងសង់ទំនប់នេះ[3]។

គម្រោងនេះនឹងចំណាយថវិកាយ៉ាងច្រើន ប៉ុន្តែកម្លាំងថាមពលអគ្គីសនីទទួលបានគឺទាប ខណៈដែលមានផលប៉ះពាល់យ៉ាងខ្លាំងទៅដល់ព្រៃឈើ សត្វព្រៃ ជីវចំរុះ និងសង្គមយ៉ាងខ្លាំង ។

ម្យ៉ាងវិញទៀត បើពិនិត្យទៅលើដំណើរនិងនីតិវិធីនៃការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាន និងសង្គមដំបូង គឺនៅមានភាពខ្វះចន្លោះប្រហោងនៃការចូលរួមរបស់ប្រជាពលរដ្ឋដែលទទួលរងផល

---

[1] ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមដំបូង «IESIA» នៃក្រុមហ៊ុនសាវ៉ាក់ (SAWAC) ខែ មករា ឆ្នាំ ២០០៨

[2] ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមដំបូង «IESIA» នៃក្រុមហ៊ុនសាវ៉ាក់ (SAWAC) ខែ មករា ឆ្នាំ ២០០៨

[3] របាយការណ៍«ការសង្ខេបពីហេតុប៉ះពាល់បរិស្ថាន និងសង្គមនៃទំនប់វារីអគ្គិសនីអារ៉ែងតំនប់និរតីនៃប្រទេសកម្ពុជា» អង្គការអភិរក្សអន្តរជាតិ និង រដ្ឋបាលព្រៃឈើនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ មិនមានឆ្នាំផលិត។

ប៉ះពាល់ក្នុងការសម្រេចចិត្ត ពោលគឺមានតែចំនួនប្រជាពលរដ្ឋមួយចំនួនតូចតែប៉ុណ្ណោះដែលបានចូលរួមពិភាក្សាជាមួយតំណាងក្រុមហ៊ុន ដូច្នេះប្រជាពលរដ្ឋមិនអាចបង្ហាញនូវយោបល់ ការព្រួយបារម្ភ និងសំណូមពរពាក់ព័ន្ធនឹងគម្រោងសាងសង់ទំនប់បានឡើយ។ ចំណែកទីតាំងដែលត្រូវផ្លាស់ប្តូរប្រជាពលរដ្ឋពីកន្លែងដែលពួកគាត់កំពុងរស់នៅទៀតសោត ជាតំបន់វាល ៧៣ ឬ វាលយន្តហោះ ជាកន្លែងដែលអាចនឹងកើតមានជម្លោះរវាងសត្វ និងមនុស្ស ព្រោះជាតំបន់សត្វដំរីឆ្លងកាត់។ជាងនេះទៅទៀត តាមរយៈការចុះកម្មសិក្សារបស់ **សម្ព័ន្ធទន្លេកម្ពុជា** (ជាសម្ព័ន្ធ ដែលធ្វើការរួមគ្នាជាមួយអង្គការជាតិ អន្តរជាតិ សហគមន៍ ដើម្បីការពារប្រព័ន្ធអេកូឡូស៊ីទន្លេ និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋដែលពឹងផ្អែកលើធនធានធម្មជាតិ)នៅតំបន់ដែលគ្រោងនឹងសាងសង់ទំនប់ចាប់ពីថ្ងៃទី ០៩ ដល់ ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣ យើងខ្ញុំសង្កេតឃើញថា ៖

- តំបន់ទីតាំងគ្រោងសាងសង់ទំនប់នេះជាតំបន់វាលរាប មិនមែនជ្រលងភ្នំដែលសាកសមនឹងការសាងសង់ទំនប់វារីអគ្គិសនី
- ជាតំបន់ដែលមានទេសភាពធម្មជាតិស្អាត និងមានទឹកធ្លាក់ច្រើនកន្លែងដែលសមស្របជាតំបន់រមនីយដ្ឋានទេសចរណ៍ធម្មជាតិ
- តំបន់នេះមានប្រជាពលរដ្ឋដែលជាជនជាតិដើមភាគតិច "ជង" រស់នៅច្រើន ជាពិសេសគឺស្ត្រី និងកុមារ ដែលអាចនឹងទទួលរងផលប៉ះពាល់ខ្លាំងជាងគេដោយសារពួកគាត់រស់នៅផ្ទាល់ និងជិតស្និតទៅលើធនធានធម្មជាតិក្នុងតំបន់នោះ។ស្ត្រីនៅតំបន់នោះមានកំរិតវប្បធម៌ទាប រស់នៅដោយធ្វើចំការ(ស្រែ) និងពឹងផ្អែកទាំងស្រុងពីផលព្រៃឈើតាមបែបប្រពៃណីដ៏ល្អផូរផង់ ។ អាចនិយាយបានថា ធនធានធម្មជាតិជាជីវិតរបស់សហគមន៍នៅតំបន់នោះ តាមរយ:វប្បធម៌ផ្សារភ្ជាប់យ៉ាងជ្រៅទៅក្នុងបេះដូងរបស់ប្រជាជន។ ជាឧទាហរណ៍ មានកុមារាអាយុ១០ឆ្នាំម្នាក់បាននិយាយថា «គាត់ចង់បានធម្មជាតិជាជាងទំនប់វារីអគ្គីសនីពីព្រោះព្រៃឈើ និងធនធានធម្មជាតិជារបស់គាត់មិនមែនជារបស់នរណាម្នាក់ទេ»។

អាស្រ័យដូចនេះយើងខ្ញុំមានកិត្តិយសសូមគោរពជម្រាបជូន សម្តេច មេត្តាជ្រាបបន្ថែមទៀតថា ប្រជាពលរដ្ឋ ក៏ដូចជាសង្គមស៊ីវិល និងអង្គការជាដៃគូ មានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះការបាត់បង់នូវទំនៀមទំលាប់ ប្រពៃណី និងការប្រតិបត្តិប្រចាំថ្ងៃរបស់បងប្អូនជនជាតិដើម "ជង" ដូចជា ចំការវិលជុំ ព្រៃអារក្ស ផ្នូរបុព្វបុរស លំនៅដ្ឋាន និងព្រៃឈើដែលជាកន្លែងទទួលអនុផលប្រចាំថ្ងៃរបស់ពួកគាត់។

តំបន់ដែលគ្រោងនឹងសាងសង់ទំនប់ គឺជាតំបន់ដែលមានសក្តានុពលផ្នែកធម្មជាតិកម្រមួយបន្ទាប់ពីព្រៃអាម៉ាហ្សូន Amazon ដែលមិនអាចរកបាននៅតាមបណ្តាប្រទេសនានាក្នុងអាស៊ីភាគអាគ្នេយ៍។ តំបន់ឆាយអារ៉ែង ជាតំបន់ដែលមានសម្រស់ស្រស់ស្អាត សំបូរទៅដោយព្រៃឈើ រុក្ខជាតិ ជីវចំរុះ សត្វព្រៃកម្រដែលជិតនឹងផុតពូជ ដែលមិនអាចកាត់ថ្លៃបាន ហើយជាតំបន់មួយដែលសាកសមបំផុតក្នុងការបង្កើតជា***តំបន់ទេសចរណ៍តាមបែបធម្មជាតិ*** ដែលនឹងបង្កើនចំណូលថវិកាជាតិ និងប្រជាពលរដ្ឋនៅទីនោះផងដែរ។

អាស្រ័យដូចនេះ យើងខ្ញុំសូមស្នើសុំសម្តេច មេត្តាធ្វើការពិចារណាក្នុងការដាក់តំបន់នេះជា ***តំបន់ទេសចរណ៍ធម្មជាតិ***ដើម្បីឲ្យប្រជាពលរដ្ឋខ្មែរ ក៏ដូចជាជនជាតិដើមភាគតិចបានរស់នៅពឹងលើសម្បត្តិធម្មជាតិនេះ និងសម្រាប់បន្តដល់កូនចៅជំនាន់ក្រោយរបស់ពួកគាត់។

សូមសម្តេចមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីយើងខ្ញុំ។

ធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១៣

**<u>តំណាង « សម្ព័ន្ធទន្លេកម្ពុជា » ៖</u>**

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា

បណ្តាញការពារទន្លេសេសាន ស្រែពក សេកុង

សម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល

សមាគមថែរក្សាបរិស្ថាន និងវប្បធម៌

អង្គការស្ម័គ្រចិត្តដើម្បីសង្គម

អង្គការថែរក្សាជនជាតិដើមភាគតិចកម្ពុជា

អង្គការអភិវឌ្ឍនិសេដ្ឋកិច្ចសហគមន៍

អង្គការអាដហុក

សមាគមន៍កសិករខ្មែរ

អង្គការអភិវឌ្ឍន៍ជនបទភូមិភាគឦសាន

អង្គការមាតាធម្មជាតិ

អង្គការពន្លកខ្មែរ

អង្គការម្លប់ព្រហ្មវិហារធម៌

អង្គការសហប្រតិបត្តិការបរិស្ថាន និង ទេសចរណ៍

**ចម្លងជូន៖**

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ក្រសួងបរិស្ថាន

ក្រសួងទេសចរណ៍

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

ក្រសួងកិច្ចការនារី

ក្រសួងអភិវឌ្ឍន៍ជនបទ

អាជ្ញាធរអគ្គិសនីកម្ពុជា

ស្ថានទូតចិន នៅប្រទេសកម្ពុជា

អ្នកសារព័ត៌មានជាតិ និង អន្តរជាតិ

*ផ្ទះលេខ ៩-១១ ផ្លូវ ៤៧៦ ទួលទំពូង១ ភ្នំពេញ ប្រអប់សំបុត្រលេខ ២២៩៥ ភ្នំពេញ-៣ # 9-11, St476, Toul Tompoung1,Phnom Penh, P.O. Box 2295 Phnom Penh-3*

*Tel: (855) 23 214 429 Fax: (855) 23 994 063*